# បណ្តាញសភានៃចលនាមិនចូលបក្សសម្ព័ន្ធ(NAM) និងសន្និបាតអន្តរសភាអាស៊ាន(AIPA) ចុះអនុស្សរណៈនៃការយោគយល់គ្នា




បណ្តាញសភានៃចលនាមិនចូលបក្សសម្ព័ន្ធ និងសន្និបាតអន្តរសភាអាស៊ានចុះអនុស្សរណៈនៃការយោគយល់គ្នា

MENAFN ថ្ងៃអង្គារ ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣

លោកស្រី Sahiba Gafarova ប្រធានសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់ និងជាប្រធានបណ្តាញសភានៃចលនាមិនចូលបក្សសម្ព័ន្ធ(NAM) បានចួបជាមួយលោកស្រី Siti Rozaimeriyanty Dato Haji Abdul Rahman អគ្គលេខាធិការសន្និបាតអន្តរសភាអាស៊ាន(AIPA) ក្នុងអំឡុងពេលបំពេញទស្សនកិច្ចការងារ ទៅកាន់រាជធានីម៉ាណាម៉ា នៃព្រះរាជាណាចក្របារ៉ែន។

កិច្ចសហប្រតិបត្តិការកម្រិតខ្ពស់រវាងសភាអាស៊ែបៃហ្សង់ និងសន្និបាតអន្តរសភាអាស៊ាន (AIPA) ត្រូវបានកត់សម្គាល់ក្នុងអំឡុងពេលនៃជំនួប។ ការផ្តល់ឋានៈជាអ្នកសង្កេតការណ៍ដល់សភាអាស៊ែបៃហ្សង់ក្នុង AIPA កាលពីឆ្នាំ២០២២ ក៏ត្រូវបានលើកឡើងផងដែរ។ គួរកត់សម្គាល់ថា ជាទូទៅសភាត្រូវរង់ចាំពី ២ ទៅ៣ឆ្នាំ ទើបទទួលបានឋានៈមួយនេះ ប៉ុន្តែការដាក់ពាក្យរបស់សភាអាស៊ែបៃហ្សង់ត្រូវបានអនុម័តភ្លាមៗតែម្តង។

លោកស្រី Gafarova ក្នុងនាមជាប្រធានបណ្តាញសភា NAM បានកត់សម្គាល់ថា បណ្តាញសភាមានចំណាប់អារម្មណ៍ក្នុងការចាប់ផ្តើមសកម្មភាពចំណងទាក់ទងជាមួយស្ថាប័នអន្តរសភា ក្នុងនោះរួមទាំង AIPA ផងដែរ។ ពាក់ព័ន្ធនឹងសកម្មភាពរបស់បណ្តាញសភា NAM លោកស្រីបានកត់សម្គាល់ពីការគាំទ្រជាទូទៅពីអន្តរជាតិចំពោះគំនិតផ្តួចផ្តើមដ៏សំខាន់ លេចជារូបរាងឡើងពីសំណាក់លោក Ilham Aliyev ប្រធានាធិបតីអាស៊ែបៃហ្សង់ក្នុងនាមលោកជាប្រធានចលនាមិនចូលបក្សសម្ព័ន្ធ(NAM)។ លោកស្រី Gafarova ក៏បានលើកឡើងផងដែរ ពីកិច្ចប្រជុំបង្កើតបណ្តាញសភា NAM នៅក្នុងទីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញក្នុងឆ្នាំ២០២១ ហើយសន្និសីទលើកទី១ ធ្វើឡើងនៅក្នុងទីក្រុងបាគូ ប្រទេសអាស៊ែបៃហ្សង់ និងត្រៀមរៀបចំធ្វើសន្និសីទលើកទី២ នៅក្នុងទីក្រុងម៉ាណាម៉ា ប្រទេសបារ៉ែន។

លោកស្រីអគ្គលេខាធិការសន្និបាតអន្តរសភាអាស៊ាន(AIPA) បានវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យរបស់អាស៊ែបៃហ្សង់ក្នុងនាមជាប្រធានបណ្តាញសភា NAM និងបានកត់សម្គាល់ពីការគាំទ្រជាទូទៅពីអន្តរជាតិ នៃការចាត់វិធានការរបស់អាស៊ែបៃហ្សង់ដើម្បីធានាការអភិវឌ្ឍស្ថាប័នបណ្តាញសភា NAM។ លើសពីនេះទៀត ការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកបានធ្វើឡើងលើកិច្ចការនៃផលប្រយោជន៍ទៅវិញទៅមក។ ជំនួបខាងលើបានបញ្ចប់ដោយការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MoU) រវាងបណ្តាញសភានៃចលនាមិនចូលបក្សសម្ព័ន្ធ NAM និងសន្និបាតអន្តរសភាអាស៊ាន(AIPA)៕

*ព័ត៌មានសភាទ្វីបអឺរ៉ុប ១៤-០៣-២៣- ឈាវ សុផាត*

ប្រែសម្រួលពី៖ https://menafn.com/1105759710/NAM-Parliamentary-Network-ASEAN-Inter-Parliamentary-Assembly-Sign-Mou

# NAM Parliamentary Network, ASEAN Inter-Parliamentary Assembly Sign Mou

(MENAFN- Trend News Agency) BAKU, Azerbaijan, March 13. Chair of Azerbaijan's Milli Majlis (Parliament) Sahiba Gafarova met with Secretary General of the ASEAN Inter-Parliamentary Assembly (AIPA) Siti Rozaimeriyanty Dato Haji Abdul Rahman during a working visit to the capital of the Kingdom of Bahrain, Manama, trend reports via the parliament.

The high level of cooperation between the Azerbaijani Parliament and the ASEAN Inter-Parliamentary Assembly was noted during the meeting.

In addition, the granting of observer status to the Parliament of Azerbaijan in the ASEAN Inter-Parliamentary Assembly last year was also mentioned. It was noted that usually, parliaments have to wait for 2-3 years to obtain this status, whereas Azerbaijan's application was endorsed instantly.

Sahiba Gafarova, as Chair of the Parliamentary Network of the Non-Aligned Movement (NAM), noted that the Network is interested in striking up active ties with inter-parliamentary entities, including the ASEAN Inter-Parliamentary Assembly.

Speaking about the activities of the NAM Parliamentary Network, she noted the broad international support for the significant initiatives brought forth by President Ilham Aliyev of Azerbaijan in his capacity as the Chair of the NAM.

Sahiba Gafarova also spoke about the founding meeting of the Network in Madrid in 2021, its first conference held in Baku, and the preparations made for the second conference that is due to take place in the Bahraini capital on March 13.

She also gave detailed information about the Network's growing cooperation with other inter-parliamentary organizations. Gafarova noted that the NAM Parliamentary Network already has observer status in three inter-parliamentary organizations: the Asian Parliamentary Assembly, the Parliamentary Union of the

Member States of the Organization of Islamic Cooperation, and the Arab Parliament.

The secretary general of the ASEAN Inter-Parliamentary Assembly highly appreciated Azerbaijan's successful chairmanship of the NAM Parliamentary Network, and noted the broad international approval of the steps taken by Azerbaijan to ensure the institutional development of the Network.

Further, an exchange of opinions took place on other issues of mutual interest. The meeting ended with the signing of a Memorandum of Understanding (MoU) between the Parliamentary Network of the Non-Aligned Movement and the ASEAN Inter-Parliamentary Assembly.

https://menafn.com/1105759710/NAM-Parliamentary-Network-ASEAN-Inter-Parliamentary-Assembly-Sign-Mou